ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៣ ១៩ · បល.សជណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ថ្ងៃអង្គារ ១០កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាសម្រាប់បម្រើការងារនៅ ទីស្តីការក្រសួងរ៉ែ និង ថាមពល និង នៅតាមបណ្តាមន្ទីររ៉ែ និង ថាមពលរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០១៩

ក្រសួងរ៉ែ និង ថាមពល សូមជូនដំណឹងដល់សាធារណជន និង មន្ត្រីជាប់កិច្ចសន្យា ដែលបម្រើការងារជូនក្រសួងរ៉ែ និង ថាមពលក្នុងឆ្នាំ២០១៨ ទាំងអស់ជ្រាបថា សម្រាប់ឆ្នាំ២០១៩ ក្រសួងរ៉ែ និង ថាមពល ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន ២០០នាក់ ឱ្យចូលបម្រើការងារនៅទីស្តីការក្រសួង និង នៅតាមបណ្តាមន្ទីររ៉ែ និង ថាមពលរាជធានី-ខេត្ត ដែលមានតម្រូវការដូចខាងក្រោម៖

**ក.មុខតំណែង**

១. ជំនួយការថ្នាក់ដឹកនាំ
២. ជំនួយការអង្គភាព ដែលមានជំនាញ ឬ ចំណេះដឹងផ្នែករដ្ឋបាល សេដ្ឋកិច្ច-គណនេយ្យ នីតិសាស្ត្រ និង ជំនាញផ្សេងៗពាក់ព័ន្ធនឹងវិស័យ រ៉ែ ថាមពល និងប្រេងកាត
៣. អ្នកធ្វើអនាម័យ អ្នកបើកបរ និងសន្តិសុខ

**ខ.អង្គភាព និង ចំនួនដែលជ្រើសរើស**

*ខ ១.នៅទីស្តីការក្រសួង៖* ត្រូវការជ្រើសរើសចំនួន ១០៥កន្លែង។

*ខ.២ នៅមន្ទីររ៉ែ និង ថាមពលខេត្ត៖* ត្រូវការជ្រើសរើសចំនួន ៩៥កន្លែង តាមអង្គភាពដូចខាងក្រោម៖

| ល.រ | អង្គភាព | ចំនួន | ល.រ | អង្គភាព | ចំនួន |
|---|---|---|---|---|---|
| ១ | មន្ទីររ៉ែ និងថាមពលខេត្តបន្ទាយមានជ័យ | ៣ | ៥ | មន្ទីររ៉ែ និងថាមពលខេត្តកំពង់ស្ពឺ | ៣ |
| ២ | មន្ទីររ៉ែ និងថាមពលខេត្តបាត់ដំបង | ៤ | ៦ | មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ | ៤ |
| ៣ | មន្ទីររ៉ែ និងថាមពលខេត្តកំពង់ចាម | ៣ | ៧ | មន្ទីររ៉ែ និងថាមពលខេត្តកំពត | ៤ |
| ៤ | មន្ទីររ៉ែ និងថាមពលខេត្តកំពង់ឆ្នាំង | ៣ | ៨ | មន្ទីររ៉ែ និងថាមពលខេត្តកណ្តាល | ១ |



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

| ល.រ | អង្គភាព | ចំនួន |
|---|---|---|
| ៩ | មន្ទីររ៉ែ និងថាមពលខេត្តកោះកុង | ២ |
| ១០ | មន្ទីររ៉ែ និងថាមពលខេត្តក្រចេះ | ៤ |
| ១១ | មន្ទីររ៉ែ និងថាមពលខេត្តមណ្ឌលគីរី | ៥ |
| ១២ | មន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ | ២ |
| ១៣ | មន្ទីររ៉ែ និងថាមពលខេត្តព្រះវិហារ | ៥ |
| ១៤ | មន្ទីររ៉ែ និងថាមពលខេត្តព្រៃវែង | ៥ |
| ១៥ | មន្ទីររ៉ែ និងថាមពលខេត្តពោធិ៍សាត់ | ៨ |
| ១៦ | មន្ទីររ៉ែ និងថាមពលខេត្តរតនគីរី | ៣ |
| ១៧ | មន្ទីររ៉ែ និងថាមពលខេត្តសៀមរាប | ៧ |

| ល.រ | អង្គភាព | ចំនួន |
|---|---|---|
| ១៨ | មន្ទីររ៉ែ និងថាមពលខេត្តព្រះសីហនុ | ២ |
| ១៩ | មន្ទីររ៉ែ និងថាមពលខេត្តស្ទឹងត្រែង | ៥ |
| ២០ | មន្ទីររ៉ែ និងថាមពលខេត្តស្វាយរៀង | ៤ |
| ២១ | មន្ទីររ៉ែ និងថាមពលខេត្តតាកែវ | ៣ |
| ២២ | មន្ទីររ៉ែ និងថាមពលខេត្តឧត្តរមានជ័យ | ២ |
| ២៣ | មន្ទីររ៉ែ និងថាមពលខេត្តកែប | ៤ |
| ២៤ | មន្ទីររ៉ែ និងថាមពលខេត្តប៉ៃលិន | ៤ |
| ២៥ | មន្ទីររ៉ែ និងថាមពលខេត្តត្បូងឃ្មុំ | ៥ |

## គ.លក្ខខណ្ឌក្នុងការជ្រើសរើស

បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ និង មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ។

## ឃ.ទីកន្លែង និង កាលបរិច្ឆេទកំណត់នៃការទទួលពាក្យ

*ឃ.១ ទីកន្លែងនៃការទទួលពាក្យៈ*

- ចំពោះបេក្ខជនដែលស្នើសុំបម្រើការងារនៅទីស្តីការក្រសួងរ៉ែ និង ថាមពល សូមដាក់ពាក្យនៅនាយកដ្ឋានបុគ្គលិក (ជាន់ទី២) ក្រសួងរ៉ែ និងថាមពល អគារលេខ ៧៩,៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- **ចំពោះបេក្ខជនដែលស្នើសុំបម្រើការងារនៅមន្ទីររ៉ែ និង ថាមពលរាជធានី-ខេត្ត** សូមដាក់ពាក្យនៅមន្ទីររ៉ែ និង ថាមពលរាជធានី-ខេត្ត ដែលសាមីខ្លួនស្នើសុំទៅបម្រើការងារនោះ។

*ឃ.២ កាលបរិច្ឆេទកំណត់នៃការទទួលពាក្យៈ*

ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី...២៥...ខែ...មករា...ឆ្នាំ២០១៩. រៀងរាល់ថ្ងៃធ្វើការ ពេលព្រឹកចាប់ពីម៉ោង ៧:៣០ នាទី ដល់ម៉ោង ១១:០០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០ នាទី ដល់ម៉ោង ១៧:០០ នាទី។

## ង.សំណុំឯកសារ និង បែបបទដែលបេក្ខជនត្រូវបំពេញ និង ភ្ជាប់ជាមួយ

- ពាក្យសុំចូលបម្រើការងារជាមន្ត្រីជាប់កិច្ចសន្យា ចំនួន ០១ច្បាប់
- ជីវប្រវត្តិសង្ខេប មានបិទរូបថត (៤X៦) ចំនួន ០២ច្បាប់
- កិច្ចសន្យាការងារ ចំនួន ០១ច្បាប់
- សេចក្តីចម្លងសំបុត្រកំណើត ឬ អត្តសញ្ញាណបណ្ណថតចម្លងមានបញ្ជាក់ផ្លូវការ ចំនួន ០១ច្បាប់

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និង មន្ត្រីជាប់កិច្ចសន្យាដែលកំពុងបម្រើការងារទាំងអស់ ជ្រាបជាព័ត៌មាន។

**បញ្ជាក់៖** - **ពាក្យសុំចូលបម្រើការងារជាមន្ត្រីជាប់កិច្ចសន្យា** អាចទាញយកបានតាមរយៈគេហទំព័រផ្លូវការរបស់ក្រសួងរ៉ែ និង ថាមពល (www.mme.gov.kh) ឬ តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង (www.facebook.com/MMECambodia)

- **ព័ត៌មានលម្អិត** សូមមកធ្វើទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិករៀងរាល់ម៉ោងធ្វើការ ឬ តាមរយៈទូរស័ព្ទលេខ៖ ០១២ ៣២១ ០០០ ឬ ០១២ ៥៥ ៣៧ ០១ ឬ ០១០ ៧៦ ៧៨ ៧៦។

**រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល**

ស៊ុយ សែម

**កន្លែងទទួល**:

- ក្រសួងមុខងារសាធារណៈ
- គ្រប់មន្ទីររ៉ែ និង ថាមពលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ